ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ: ៥២៦ "ឃ១"
ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ: ៣២៦៨
ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខ: ១៤០៨
ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១
-សំណុំរឿងជំនុំជំរះលេខ: **២៩៩៧**
ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង៣០ នាទី ព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព ៖

ចៅក្រមជំនុំជម្រះ

-លោកស្រី [redacted] ជាចៅក្រមជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:**៣២៦៨** ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted]**សុផល** ហៅ **ធា** ភេទប្រុស កើតថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧០ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កសិករ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នស្នាក់នៅលើផ្លូវលេខ៤១ ភូមិតាដៅ ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted]**សួន** "ស្លាប់" ម្តាយឈ្មោះ [redacted]**ប៊ុត** "ស្លាប់" ប្រពន្ធឈ្មោះ [redacted]**ចាន់ដន** "**រស់**" មានកូន០៥នាក់ ជានីតិជន **ទោសពីមុន គ្មាន**។

-ឃុំខ្លួនក្នុងមណ្ឌលអប់រំកែប្រែ**ទី១** (**ម១**) តាមដីកាបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនលេខ **១៣៧២** "**ឃ១**" **ដ.ច.ន** ថ្ងៃទី**១៥** ខែវិច្ឆិកា ឆ្នាំ**២០២២** របស់ចៅក្រមជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ។

២-ឈ្មោះ [redacted]**សុខន** ភេទប្រុស កើតថ្ងៃទី**០៩** ខែតុលា ឆ្នាំ**១៩៧២** ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរគ្រូបង្រៀន ទីកន្លែងកំណើតនៅ[redacted]ខេត្តកំពង់ស្ពឺ មានទីលំនៅបច្ចុប្បន្នស្នាក់នៅលើផ្លូវលេខ៤១ ភូមិទួលតាសុខ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted]ពុំ "ស្លាប់" ម្តាយឈ្មោះ [redacted]**យ៉ុម** "ស្លាប់"ប្រពន្ធឈ្មោះ [redacted]**សុគន្ធា** "**រស់**" មានកូន០៥នាក់ ជានីតិជន **ទោសពីមុន គ្មាន**។

-ឃុំខ្លួនក្នុងមណ្ឌលអប់រំកែប្រែ**ទី១** (**ម១**) តាមដីកាបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនលេខ **១៣៧១** "**ឃ១**" **ដ.ច.ន** ថ្ងៃទី**១៥** ខែវិច្ឆិកា ឆ្នាំ**២០២២** របស់ចៅក្រមជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ។

Scanned with CamScanner

-ជាប់ចោទពីបទ **ឆបោក** និងបទ **ក្លែងបន្លំ(ស្ថាមមេដៃ)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧**,មាត្រា**៣៧៨** និងមាត្រា**៦២៦**, មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ។

-មានឈ្មោះ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** និងជនជាប់ចោទឈ្មោះ [redacted] **សុខន** មានការិយាល័យនៅអគារលេខ៣៥CD ផ្ទះលេខ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-មានឈ្មោះ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** និងជនជាប់ចោទឈ្មោះ [redacted] **សុខន** មានការិយាល័យនៅអគារលេខ២A ផ្លូវលេខ២០២ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-មានឈ្មោះមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** មានការិយាល័យនៅផ្លូវបេតុង ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-មានឈ្មោះមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុខន** មានការិយាល័យ០៦៣ ផ្លូវព្រះសីហនុ កែងផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ [redacted] **ឆលីង** [redacted] HSIU LING) ភេទស្រី កើតឆ្នាំ១៩៦៥ ជនជាតិចិនតៃវ៉ាន់ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ១៧ ផ្លូវលេខ០៨ ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

-មានឈ្មោះ [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវលីង មានការិយាល័យនៅផ្ទះលេខ១៤៣ ផ្លូវលេខ២០២ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

អង្គហេតុនៃរឿងមានដូចតទៅៈ

កាលពីអំឡុងខែមិថុនា ឆ្នាំ២០១៨ ឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន បានធានារៀបចំទិញដីពីប្រជាពលរដ្ឋជាច្រើនគ្រួសារ មានទំហំសរុប ១២៣,៧៩៧.៩៩៩ ម² (ដប់ពីរម៉ឺនបីពាន់ប្រាំពីររយកៅសិបប្រាំពីរក្បៀសប្រាំបួនរយកៅសិបប្រាំបួន) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិពង្រ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឱ្យទៅឈ្មោះ [redacted] ស៊ីវលីង (CHANG HSIU LING) ជនជាតិចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុន ហុងឡុង ស៊ូ ឯ.ក (HONG LONG SHOE CO.,LTD) ដោយឈ្មោះ [redacted] រី ទទួលបន្ទុកជាអ្នកបកប្រែផង និងជាអ្នកចុះកិច្ចសន្យាទិញលក់ដីផង ជាមួយឈ្មោះ [redacted] ស៊ីវលីង ([redacted] HSIU LING) រីឯឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន ជាអ្នកធានា ហើយរាល់ពេលទទួលប្រាក់ គឺអ្នកទាំងបីនាក់បានទៅបើកយកប្រាក់នៅធនាគារទាំងអស់គ្នាជាច្រើនលើកច្រើនសារ សរុបចំនួន ៦៦0,000 (ហុកសិបប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលប្រាក់ទាំងអស់នេះ ត្រូវបានឈ្មោះ [redacted]រី ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន យកទៅកក់ឱ្យប្រជាពលរដ្ឋបានមួយចំនួន និងអ្នកខ្លះទៀតទទួលបានគ្រប់ចំនួន និងនៅសល់ប្រជា-ពលរដ្ឋមួយចំនួនទៀតទទួលរបានប្រាក់កក់តែប៉ុណ្ណោះ។ លុះក្រោយមកឈ្មោះ [redacted] រី,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន បានរៀបចំធ្វើឯកសារលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ដោយដាក់ឈ្មោះរបស់ប្រជាពលរដ្ឋដែលបានកក់ប្រាក់នោះ គឺមានឈ្មោះ [redacted]យន ដែល ចម្លើយរបស់ឈ្មោះ [redacted]យន បានអះអាងថា នៅលើ

លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ៨២០/១៨ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ដែលមានចុះហត្ថលេខា អែភូអិពង្រ ឈ្មោះ [redacted] សុង បានប្រថាប់ត្រាដោយលោកមេឃុំស្រង់ ឈ្មោះ [redacted] ប៉ែង គឺមិនមែនស្នាមមេដៃរបស់គាត់នោះទេ ឈ្មោះ [redacted]ពៈ និងប្រពន្ធឈ្មោះ [redacted] រីណាដែល ចម្លើយអ្នកទាំងពីរបានឆ្លើយថា នៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ ៨១៧/១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨ មិនមែនស្នាមមេដៃរបស់ពួកគាត់ទេ។ ចំណែកចម្លើយរបស់ឈ្មោះ [redacted]ហ៊ិន,ឈ្មោះ [redacted] សំណាង,ឈ្មោះ [redacted] ចាន់ធឿន, ឈ្មោះ[redacted] ប៉ក់ និងឈ្មោះ [redacted] ទួច សុទ្ធតែបានឆ្លើយដូចគ្នាថា នៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលមានស្នាមមេដៃពួកគាត់នោះគឺពួកគាត់បានអះអាងថា ពុំដែលបានផ្តិតមេដៃទេ គឺពួកគាត់ធ្លាប់បានផ្តិតមេដៃលើលិខិតកក់ប្រាក់តែប៉ុណ្ណោះ ហើយឈ្មោះ [redacted] រី,ឈ្មោះ [redacted] សុខន និងឈ្មោះ [redacted] សុផល បានយកលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនេះ ទៅចុះហត្ថលេខាលោកមេភូមិពង្រ ឈ្មោះ [redacted] សុង និងលោកមេឃុំស្រង់ ឈ្មោះ [redacted] ប៉ែង ដោយលោកមេភូមិ និងលោកមេឃុំបានអះអាងថា នៅពេលចុះហត្ថលេខា គឺមានស្នាមមេដៃរបស់ប្រជាពលរដ្ឋរួចហើយ ដោយពុំបានផ្តិតមេដៃចំពោះមុខខ្លួននោះទេ ហើយខ្លួនក៏ពុំបានដឹងថា ស្នាមមេដៃទាំងអស់ជាស្នាមមេដៃរបស់នរណាឡើយ ហើយឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុផល និងឈ្មោះ[redacted] សុខន បានយកលិខិតផ្ទេរសិទ្ធិទាំងនេះទៅយកប្រាក់ពីក្រុមហ៊ុន ហុងឡុង ស្ហូ ឯ.ក (HONG LONG SHOE CO.,LTDបន្ថែមទៀត។ តែក្រុមហ៊ុនបានដឹងគំនិតទុច្ចរិតរបស់អ្នកទាំងបីខាងលើនេះ ក្រុមហ៊ុនពុំបានប្រគល់ប្រាក់ឱ្យទៀតទេ ព្រោះឈ្មោះ [redacted]រី ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន បានយកប្រាក់ពីក្រុមហ៊ុនអស់ចំនួន ៦៦០,០០០ USD (ហុកសិបប្រាំមួយម៉ឺន) ដុល្លារអាមេរិក ទៅហើយ តែប្រមូលទិញដីបានមួយចំនួនតូចតែប៉ុណ្ណោះ ប្រហែល០៥ហិចតា ឯប្រាក់បានយកពីក្រុមហ៊ុនជិតគ្រប់ចំនួនអើអរ។ ចំពោះដីដែលឈ្មោះ [redacted] រី, ឈ្មោះ [redacted]សុផល និងឈ្មោះ [redacted] សុខន បានរៀបចំទិញនោះ គឺពុំជាប់គ្នាទេ គឺមានចន្លោះប្រហោងជាច្រើនកន្លែងជាហេតុធ្វើឱ្យក្រុមហ៊ុនពុំអាចទទួលយកបានក្នុងការធ្វើអោងក្រឡើយ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋបានទទួលប្រាក់កក់នោះអះអាងថា ពួកខ្លួននៅតែលក់ដដែល តែមូលហេតុមកពីឈ្មោះ [redacted] រី ឈ្មោះ [redacted] ពៅ សុខន មិនព្រមយកប្រាក់ដែលទទួលបានពីក្រុមហ៊ុនបកឱ្យពួកខ្លួនបង្ក្រៃប់។

-**បានឃើញ** ពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីវលីង** (CHANG HSIU LING)បានបណ្តឹងចូលមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកៈសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: **១២១៩ អ.ឃ.ឆ** ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ: **២៧០៧ អ.ឃ.ឆ** ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ: **៣៧៨៧ "ឧ" ដ.ដ** ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ជា បានឆ្លើយថា៖ខ្លួនសុំប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៤៣ "ឃ១" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ត្រង់សេចក្តីសម្រេចទាំងមូលខ្លួនសុំឆ្លើយបញ្ជាក់ថា៖កាលពីថ្ងៃទី៣០

ខែមិថុនា ឆ្នាំ២០១៨ ខ្លួនពិតជាបានរៀបចំដីឲ្យក្រុមហ៊ុន ហុង ឡុងស៊ូ និងបានចុះកិច្ចសន្យាធានាដោយបុគ្គលនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ជាមួយលោកស្រី [redacted] HSIU LING ជាជនជាតិចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុន ហុង ឡុងស៊ូ ក្រោយពីធ្វើកិច្ចសន្យាធានាដោយបុគ្គលរួចមក ឈ្មោះ [redacted] រី តម្រូវឲ្យខ្លួនដាក់អចលនវត្ថុផ្ទាល់ខ្លួន ហើយក៏បានយកលិខិតបញ្ជាក់លេខ ៤៥៥/១៨ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ជាច្បាប់ដើម មានដីទំហំ ៥០មX៥០ម មានទីតាំងស្ថិតនៅភូមិតានៅឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយយកទៅដាក់តម្កល់នៅក្នុងក្រុមហ៊ុន ហុងឡុងស៊ូ ។ ក្នុងការរៀបចំដីឲ្យក្រុមហ៊ុន ហុងឡុងស៊ូ ខ្លួនមានក្រុមចំនួន១០នាក់ គឺមានឈ្មោះ [redacted] ប៊ុនធឿន អាទប្រុស, ឈ្មោះ [redacted] ពេះ អាទប្រុស, ឈ្មោះ [redacted] សាវឿត អាទប្រុស, ឈ្មោះ [redacted] អ៊ួក អាទប្រុស ,ឈ្មោះ [redacted] ប៊ុននាង អាទប្រុស ,ឈ្មោះ [redacted] សុខន អាទប្រុស, ឈ្មោះ [redacted] យ៉ន អាទប្រុស ,ឈ្មោះ [redacted] ថៃ អាទប្រុស ,ឈ្មោះ [redacted] ម៉ែត អាទប្រុស និងខ្លួន ។ ក្នុងពេលដែលទទួលរៀបចំដីឲ្យក្រុមហ៊ុននេះ ខ្លួនបានទទួលប្រាក់ចំនួន១២លើកពីឈ្មោះ [redacted] រី មិនបានទទួលប្រាក់ពីក្រុមហ៊ុននោះទេលើកទី០១នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ចំនួន ២១,០០០ (ពីរម៉ឺនមួយពាន់ដុល្លារអាមេរិក)លើកទី០២ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ចំនួន ៥៤,០០០ (ប្រាំម៉ឺនបួនពាន់ដុល្លារអាមេរិក) លើកទី០៣ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ ចំនួន ៨០,០០០ (ប្រាំបីម៉ឺនដុល្លារអាមេរិក) លើកទី០៤ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ចំនួន ៥០,០០០ (ប្រាំម៉ឺនដុល្លារអាមេរិក) លើកទី០៥ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ចំនួន១២,៤០០ (មួយម៉ឺនពីរពាន់បួនរយដុល្លារអាមេរិក) លើកទី០៦ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ចំនួន ៣៥,០០០ (បីម៉ឺនប្រាំពាន់ដុល្លារអាមេរិក) លើកទី០៧នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ចំនួន ២២០,០០០ (ម្ភៃពីរម៉ឺនដុល្លារអាមេរិក) លើកទី០៨ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៨ ចំនួន១២,៧០០ (មួយម៉ឺនពីរពាន់ប្រាំពីររយដុល្លារអាមេរិក) លើកទី០៩ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩ ចំនួន១០,៤២៥ (មួយម៉ឺនបួនរយម្ភៃប្រាំដុល្លារអាមេរិក) លើកទី១០ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) លើកទី១១ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ចំនួន ១,០០០ (មួយពាន់ដុល្លារអាមេរិក) លើកទី១២ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ចំនួន ៣,៣០០ (បីពាន់បីរយដុល្លារអាមេរិក)។ ដូច្នេះ ប្រាក់ដែលខ្លួនបានទទួលពីឈ្មោះ [redacted] រី មានសរុបចំនួន ៥១៤,៨២៥ (ហាសិបមួយម៉ឺនបួនពាន់ប្រាំបីរយម្ភៃប្រាំដុល្លារអាមេរិក)។ ក្រោយពីខ្លួនរៀបចំដីឲ្យក្រុមហ៊ុន គឺខ្លួនបានប្រគល់ដីឲ្យទៅក្រុមហ៊ុនចំនួន ០២ដង ដែលមានទំហំ ៣៣,៥៥៧ ម^{2} មានទីតាំងស្ថិតនៅភូមិពង្រ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយនៅខ្វះដីឲ្យក្រុមហ៊ុនចំនួន ០៨ ហិចតា ជាង។ ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចំនួន១៥ច្បាប់ គឺក្រុមរបស់ខ្លួនជាអ្នករៀបចំ ហើយចំពោះការធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលមានស្នាមមេដៃនៅលើលិខិតទាំង១៥ ច្បាប់នោះ គឺមានចំនួន០៦នាក់ មានឈ្មោះ [redacted] ប៊ុនធឿន,ឈ្មោះ [redacted] អ៊ួក,ឈ្មោះ [redacted] ប៊ុននាង,ឈ្មោះ [redacted] យ៉ន ,ឈ្មោះ [redacted] សុខន និងរូបខ្លួន ហើយក៏ជាអ្នកផ្តិតមេដៃនៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំនួន ១៥ច្បាប់នេះ តែស្នាមមេដៃនៅលើលិខិតផ្ទេរសិទ្ធិនោះ គឺមិនមែនជាស្នាមមេដៃរបស់ប្រជាពលរដ្ឋនោះទេ ក្នុងនោះមានចំនួន០៣គ្រួសារ គឺគ្រួសារឈ្មោះ [redacted] សំណាង,ឈ្មោះ [redacted] យ៉ន និងឈ្មោះ [redacted] ពេះ ពិតជាមានដីនៅក្នុងចំណោម ១៥ គ្រួសារប្រាកដមែន។ ហើយបីគ្រួសារនោះក៏បានផ្តិតមេដៃផ្តាល់ប្រគល់ដីឲ្យដែរចំណែកអ្នកដែលរៀបចំសរសេរនៅលើលិខិតផ្ទេរសិទ្ធិប្រើប្រាស់ដីធ្លីនោះ គឺមានឈ្មោះ ម៉ុយ និងឈ្មោះ [redacted] ម៉ែត ហើយអ្នកដែលយកឯកសារលិខិតទាំងនោះទៅ

ឲ្យលោកមេឃុំ មេភូមិចុះហត្ថលេខា គឺមានឈ្មោះ [redacted] ប៊ុនធាង និងឈ្មោះ [redacted] យ៉ន។ ចំពោះការរៀបចំនៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចំនួន១៥ច្បាប់នោះ ពុំមានការជាប់ពាក់ព័ន្ធជាមួយឈ្មោះ [redacted] រីនោះទេ ឈ្មោះ [redacted] រី គ្រាន់តែទូរស័ព្ទប្រាប់ក្រុមហ៊ុននិងឲ្យផ្តិតមេដៃនៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំនួន ១៥ច្បាប់ នោះដោយខ្លួនឯងទៅ ដោយមិនចាំបាច់មានស្នាមមេដៃរបស់ប្រជាពលរដ្ឋនោះទេ រួចហើយក៏យកលិខិតទាំងនោះទៅឲ្យឈ្មោះ [redacted]រី ដើម្បីឲ្យឈ្មោះ [redacted] រី យកទៅបើកប្រាក់ពីថៅកែរបស់គាត់។ ចំពោះប្រាក់ដែលខ្លួនទទួលបានចំនួន១២ដង សរុបចំនួន ៥១៤.៨២៥ (ហាសិបមួយម៉ឺនបួនពាន់ប្រាំបីរយម្ភៃប្រាំដុល្លារអាមេរិក) គឺមានតែរូបខ្លួន និងឈ្មោះ [redacted] សុខន ហើយប្រាក់ទាំងនោះ គឺខ្លួនមិនបានទទួលផ្ទាល់ពីក្រុមហ៊ុននោះទេ គឺតាមរយៈឈ្មោះ [redacted] រី។ចំពោះឈ្មោះ [redacted] រី បានទទួលប្រាក់ពីក្រុមហ៊ុនចំនួនប៉ុន្មានដងខ្លួនពុំបានដឹងទេ ហើយខ្លួនក៏មិនដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុននោះដែរ។ ចំពោះការរៀបចំលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំនួន១៥ច្បាប់ខាងលើនោះ គឺឈ្មោះ [redacted] រី ជាអ្នកបង្គាប់បញ្ជាឲ្យក្រុមរបស់ខ្លួនធ្វើ ហើយឈ្មោះ [redacted] រី ក៏បានសន្យាថាបើបើកប្រាក់បានពីក្រុមហ៊ុន គឺយកប្រាក់ទាំងអស់ទៅឲ្យប្រជាពលរដ្ឋទាំង ១៥ គ្រួសារ ទើបចប់រឿងហើយ។ ខ្លួនសូមឱ្យតុលាការលើកលែងការចោទប្រកាន់មកលើខ្លួនផង ដោយសាររឿងនេះមានលក្ខណៈជាន់គ្នាទៅនឹងសំណុំរឿងព្រហ្មទណ្ឌលេខ៦៣៩ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ រួចរាល់ហើយ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺរូបខ្លួនយល់ព្រមចរចារកដោះស្រាយជាមួយគ្នា ចំពោះបញ្ហាកន្លងមក។

-ជនជាប់ចោទឈ្មោះ [redacted] **សុខន** បានឆ្លើយថាៈខ្លួនសុំប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៤៣ **"ឃ១"** ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ត្រង់សេចក្តីសម្រេចទាំងមូល ខ្លួនសុំឆ្លើយបញ្ជាក់ថាៈកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ខ្លួនពិតជាបានរៀបចំដីឲ្យក្រុមហ៊ុន ហុង ឡុងស៊ូ និងបានចុះកិច្ចសន្យាធានាដោយបុគ្គល នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ជាមួយលោកស្រី [redacted] LING ជាជនជាតិចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុន ហុង ឡុងស៊ូ។ ក្រោយពីធ្វើកិច្ចសន្យាធានាដោយបុគ្គលរួចមក ឈ្មោះ [redacted] រី តម្រូវឲ្យខ្លួនដាក់អចលនវត្ថុផ្ទាល់ខ្លួន ចំនួន ០៤ កន្លែង ទី១ អចលនវត្ថុដីទំហំ ៦៦មX៤៣ម មានទីតាំងស្ថិតនៅភូមិបប្រវឹកពង ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលមានលិខិតបញ្ជាក់ការកាន់កាប់អចលនទ្រព្យលេខ ៣៧២/២១ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ចេញដោយលោកមេឃុំទឹកល្អក់ ទី២ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ស ០០៧៧០៨ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ចេញដោយប្រធានមន្ទីរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ ទី៣អចលនវត្ថុដីស្រែទំហំ ២៧មX៤៨ម មានទីតាំងស្ថិតនៅភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខ ១៦០០/១៦ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ចេញដោយមេឃុំព្រៃញាតិ ,ទី៤អចលនវត្ថុ ដីស្រែ ទំហំ ៣៥មX៥០ម មានទីតាំងស្ថិតនៅភូមិបាក់ក ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខ ៧០៣/១៦ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ចេញដោយមេឃុំព្រៃញាតិ។ ដោយយកទៅដាក់តម្កល់នៅក្នុងក្រុមហ៊ុនហុងឡុងស៊ូ ចំពោះដីទាំងបួនកន្លែង ដែលខ្លួនដាក់តម្កល់នៅក្នុងក្រុមហ៊ុន គឺតម្លៃប្រហែលពាន់៧៥,២០០ (សាមសិបប្រាំពីរម៉ឺនបួនពាន់ពីររយដុល្លារអាមេរិក) ក្នុងការរៀបចំដីឲ្យក្រុមហ៊ុន ហុងឡុងស៊ូ ខ្លួនមានក្រុមចំនួន១០នាក់ គឺមានឈ្មោះ [redacted] សុផល, ឈ្មោះ [redacted] ប៊ុនធឿន, ឈ្មោះ [redacted] អ៊ូក, ឈ្មោះ [redacted] ប៊ុនធាង , ឈ្មោះ [redacted] យ៉ន, ឈ្មោះ [redacted]

ម៉ែត, ឈ្មោះ [redacted]ពេះ,ឈ្មោះ [redacted] សាវ៉ែត ,ឈ្មោះ [redacted]ថៃ និងរូបខ្លួន។ ក្នុងពេលដែលខ្លួនទទួលរៀបចំដីឲ្យក្រុមហ៊ុន នេះ ខ្លួនបានទទួលប្រាក់ចំនួន ១២ដង ពីឈ្មោះ [redacted]រី មិនបានទទួលប្រាក់ពីក្រុមហ៊ុននោះទេ ហើយប្រាក់ដែលខ្លួន បានទទួលទាំង ១២លើក ពីឈ្មោះ [redacted]រី មានចំនួនសរុបចំនួន ៥១៤,៨២៥ (ហាសិបមួយម៉ឺនបួនពាន់ប្រាំបីរយ ម្ភៃប្រាំដុល្លាអាមេរិក)។ ក្រោយពីខ្លួនរៀបចំដីឲ្យក្រុមហ៊ុន គឺខ្លួនបានប្រគល់ដីឲ្យទៅក្រុមហ៊ុនចំនួន ០២ដង លើកទី១ មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីចំនួន០៨ប័ណ្ណ ,និងលើកទី២ ចំនួន០៣ប័ណ្ណ សរុបមានចំនួន១១ប័ណ្ណ ដែលមានដី ទំហំ ៣៣,៥៥៧ម^2 មានទីតាំងស្ថិតនៅភូមិពង្រ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងនៅភូមិក្រាំងធ្នង ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយនៅខ្វះដីឲ្យក្រុមហ៊ុនចំនួន ០៨ហិចតា ជាងទៀត។ ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី ចំនួន១៥ច្បាប់ គឺក្រុមរបស់ខ្លួនជាអ្នករៀបចំ ហើយចំពោះការធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលមានស្នាមមេដៃនៅលើលិខិតទាំង ១៥ច្បាប់ នោះ គឺមានចំនួន០៥នាក់ មានឈ្មោះ [redacted] ប៊ុនធឿន,ឈ្មោះ [redacted] សុផល,ឈ្មោះ [redacted] ប៊ុននាង,ឈ្មោះ [redacted]យ៉ន,ឈ្មោះ [redacted]អ៊ូក គឺជាអ្នករៀបចំធ្វើ ប៉ុន្តែខ្លួនពុំបានចូលរួមធ្វើនោះទេ ដោយសារពេលនោះខ្លួនមានជម្ងឺប្រចាំកាយ ។ ចំពោះនៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំនួន ១៥ ច្បាប់ ដែលមានស្នាមមេដៃនោះគឺខ្លួនពុំបានដឹងទ ។ ចំណែកអ្នកដែលរៀបចំសរសេរនៅលើលិខិតផ្ទេរសិទ្ធិប្រើប្រាស់ដីធ្លីនោះ គឺមានឈ្មោះ[redacted] អ៊ូក និងឈ្មោះ[redacted] ម៉ែត ហើយអ្នកដែលយកឯកសារលិខិតទាំងនោះទៅឲ្យឈ្មោះមេឃុំ មេភូមិចុះ ហត្ថលេខា គឺមានឈ្មោះ [redacted] ប៊ុននាង និងឈ្មោះ[redacted] យ៉ន។ ក្នុងការរៀបចំនៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចំនួន១៥ច្បាប់នោះ គឺឈ្មោះ [redacted]រី គ្រាន់តែទូរស័ព្ទប្រាប់ទៅឈ្មោះ[redacted] សុផល និងឈ្មោះ[redacted]ប៊ុនធឿន ឲ្យរៀបចំ ផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិចំនួន១៥ច្បាប់នោះធ្វើឲ្យបានដើម្បីប្រញាប់ទៅបើកប្រាក់នៅក្រុមហ៊ុន។ ចំពោះលិខិតផ្ទេរ សិទ្ធិទាំង ១៥ ច្បាប់ នោះ ឈ្មោះ [redacted] សុផល និងឈ្មោះ[redacted] ប៊ុនធឿន រៀបចំយ៉ាងណានោះខ្លួនមិនបានដឹងទេ។ សព្វថ្ងៃក្រុមហ៊ុនបានដាក់វត្ថុការពារនៅសាលាដំបូងរាជធានីភ្នំពេញ ដោយធ្វើការឃាត់នៅលើដីរបស់ខ្លួនចំនួន ០៥ កន្លែងខ្លួនត្រូវបានឈ្មោះ [redacted]រី ប្តឹងពីបទ រំលោភលើទំនុកចិត្ត និងក្លែងបន្លំ ក្នុងករណីដែលពាក់ព័ន្ធទៅនឹងលិខិតផ្ទេរ សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំនួន ១៥ ច្បាប់ លើស្នាមមេដៃរបស់ប្រជាពលរដ្ឋ និងពាក់ព័ន្ធលើប្រាក់ដែលក្រុមរបស់ ខ្លួនទទួលបានចំនួន ១២ ដង ទៅសាលាដំបូងខេត្តកំពង់ស្ពឺ ហើយសាលាដំបូងខេត្តកំពង់ស្ពឺ ក៏បានធ្វើការចោទប្រកាន់ លើរូបខ្លួន ហើយចៅក្រមស៊ើបសួរបានធ្វើការកោះហៅមកសាកសួរ និងបានសម្រេចមិនធ្វើការឃុំខ្លួនលើរូបខ្លួន នោះទេ ហើយរឿងនេះគេបានបញ្ជូនទៅជំនុំជម្រះរួចហើយ ប៉ុន្តែឈ្មោះ[redacted] សុផល បានប្រាប់ថា តុលាការបានបើក សវនាការនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០២ រសៀល តែខ្លួនពុំបានទទួលដីការកោះហៅពីតុលាការ ខេត្តកំពង់ស្ពឺនោះទេ ។ ចំពោះរឿងខាងលើនេះគឺរូបខ្លួនយល់ព្រមចរចាជាមួយដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ពេល ហើយ ម្យ៉ាងវិញទៀតខ្លួនមានជំងឺប្រចាំកាយ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវលីង [redacted] HSIU LING) បានឆ្លើយនៅ ដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខាងក្រុមហ៊ុនបានប្រគល់ប្រាក់ថ្លៃទិញដី ឲ្យទៅឈ្មោះ[redacted]រី ,ឈ្មោះ[redacted] សុផល និងឈ្មោះ [redacted]សុខន សរុបចំនួន ៥៦0,000 (ហាសិបប្រាំមួយម៉ឺនដុល្លាអាមេរិក) ក្រោយមកឈ្មោះ [redacted]រី បានទៅសុំ ប្រាក់ថ្លៃដីបន្ថែមចំនួន ១00,000 (ដប់ម៉ឺនដុល្លាអាមេរិក) សរុបទាំងអស់ ចំនួន ៦៦0,000 (ហុកសិបប្រាំមួយម៉ឺន

ដុល្លារអាមេរិក) និងឈ្មោះ [redacted] រី បានយកថ្លៃចាក់ដីចំនួន ១១០,000 (ដប់មួយម៉ឺនដុល្លារអាមេរិក) បន្ថែមទៀត។ ក្នុងការទិញលក់ដីនេះ អ្នកទាំងបីគឺបានធ្វើការប្រគល់ដី និងផ្ទេរកម្មសិទ្ធិដ៏ត្រឹមត្រូវតាមលិខិតផ្ទេរសិទ្ធិចំនួន ៣៣,៥៩១ម៉ែ ដែលលិខិតផ្ទេរសិទ្ធិនេះមានចុះហត្ថលេខាត្រឹមសាលាស្រុក ហើយអ្នកទាំងបីនៅខ្វះដី ចំហំ ០៩ ហិចតា ទៀតដែលមិនប្រគល់ឱ្យក្រុមហ៊ុន។ ពាក់ព័ន្ធទៅនឹងឯកសារផ្ទេរសិទ្ធិក្លែងក្លាយទាំង ១៤បណ្ណ ដែលជាភស្តុតាងក្នុងការ ដាក់ពាក្យបណ្តឹងនេះ ក្រុមហ៊ុនបានមកពីឈ្មោះ [redacted] រី ផ្ញើឱ្យតាមរយៈវីឆាត ហើយក្រុមហ៊ុន ឃើញឯកសារចុះហត្ថលេខាត្រឹមមេឃុំ ក្រុមហ៊ុនបានទាមទារឱ្យចុះហត្ថលេខាដល់សាលាស្រុកតាមកិច្ចសន្យាទិញលក់ ហើយក្រុមហ៊ុនក៏បានប្រាប់ទៅឈ្មោះ [redacted] រី ឱ្យចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិស្រុក ដើម្បីឱ្យស្របតាមកិច្ចសន្យា ទន្ទឹមនឹងនេះ ឈ្មោះ [redacted] រី បានសុំបើកប្រាក់នៅដំណាក់កាល ទី០៣ បន្ថែមចំនួន ២៨០,000 (ម្ភៃប្រាំបីម៉ឺនដុល្លារអាមេរិក) ពេលនោះក្រុមហ៊ុនក៏បានប្រគល់ឱ្យ ហើយការប្រគល់ប្រាក់ឱ្យ គឺមានឈ្មោះ [redacted] រី ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន មកទទួលក្រោយពីប្រគល់លុយហើយក្រុមហ៊ុនរង់ចាំលិខិតផ្ទេរសិទ្ធិនោះយូរពេក មានរយៈពេលជាង០១ឆ្នាំ ទើបក្រុមហ៊ុនទៅស្រាវជ្រាវដល់ទីតាំងដី ហើយជួបម្ចាស់ដីបានប្រាប់ថា មិនបានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីនោះទេទើបក្រុមហ៊ុនដឹងថា ដីចំនួន ១៤ បណ្ណ នោះគឺក្លែងក្លាយ។ ក្រោយដឹងហើយ ក្រុមហ៊ុនបានហៅអ្នកទាំងបីមកធ្វើការដោះស្រាយរឿងឯកសារក្លែងក្លាយនេះ ហើយអ្នកទាំងបីបានរៀបចំឯកសារឱ្យក្រុមហ៊ុនផ្តិតមេដៃទទួលដីម្តងទៀត គឺមានដីប្រគល់មកឱ្យក្រុមហ៊ុន បានចំនួន ០៣ ហិចតា ដូចការរៀបរាប់ខាងលើ រួចក្រុមហ៊ុនក៏មិនអាចទទួលយកបាន ក៏ដាក់ពាក្យបណ្តឹងមកតុលាការតែម្តង។ ចំពោះឯកសារក្លែងក្លាយចំនួន ១៤ បណ្ណ ឈ្មោះ [redacted] រី មិនដែលប្រាប់ក្រុមហ៊ុនថាជាឯកសារក្លែងក្លាយទេ គឺក្រុមហ៊ុនដឹងដោយខ្លួនឯង នៅពេលដែលក្រុមហ៊ុនចុះទៅស៊ើបដល់ទីតាំងដី។ រាល់ការចំនាក់ចំនងក្នុងការទិញដីនេះ គឺក្រុមហ៊ុនធ្វើផ្ទាល់ជាមួយឈ្មោះ [redacted] រី ហើយឈ្មោះ [redacted] រី មិនមែនគ្រាន់តែជាអ្នកទទួលបកប្រែផ្តែកម្បុងដីនោះទេ។ ចំពោះប្រាក់ចំនួន ១១០,000 (ដប់មួយម៉ឺនដុល្លារអាមេរិក) គឺឈ្មោះ [redacted] រី ទទួលពីក្រុមហ៊ុនធានាក្នុងការចាក់ដីឱ្យស្មើ លើដី១២ហិចតា ដែលត្រូវទិញ ហើយប្រាក់នេះក្រុមហ៊ុនបានប្រគល់ឱ្យទៅឈ្មោះ [redacted] រី រួចរាល់អស់ហើយ បន្ទាប់ពេលដែលឈ្មោះ [redacted] រី អះអាងថាប្រមូលទិញដី១២ហិចតា ហើយប្រាក់ចំនួន ១១០,000 (ដប់មួយម៉ឺនដុល្លារអាមេរិក) មិនមានការពាក់ព័ន្ធជាមួយនឹងឈ្មោះ សួន សុផល និងឈ្មោះ [redacted] សុខ លើចំណែកនៃការទិញដីនោះទេ។ ចំពោះដី ០៣ ហិចតា ដែលជនជាប់ចោទទាំងបីនាក់នេះបានផ្ទេរសិទ្ធិប្រគល់មកឱ្យក្រុមហ៊ុន ជាដីដែលមិនជាប់គ្នា ដោយមិនត្រូវតាមកិច្ចសន្យាទិញលក់ ដូច្នេះក្រុមហ៊ុនទទួលយកអត់បានទេ ក្រុមហ៊ុនយល់ព្រមប្រគល់ដីនេះឱ្យទៅ អ្នកទាំងបីនាក់វិញ នៅពេលអ្នកទាំងបីបានសងប្រាក់មួយ (គុណបី) តាមកិច្ចសន្យា ដែលស្មើនឹងចំនួន ១,៩៨0,000 (មួយលានប្រាំបួនសែនប្រាំបីម៉ឺនដុល្លារអាមេរិក) នៃចំនួនទឹកប្រាក់ដែលគាត់បានទទួលចំនួន ៦៦0,000 (ហុកសិបប្រាំមួយម៉ឺនដុល្លារអាមេរិក) ដូចការទាមទារ និងសំណូមពរ សូមឱ្យតុលាការផ្តន្ទាទោសឈ្មោះ [redacted] រី ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន តាមច្បាប់ និងសុំឱ្យចាប់ឃុំខ្លួន ជនទាំងបីនាក់នេះព្រមទាំងបង្គាប់ឱ្យអ្នកទាំងបីនាក់ សងប្រាក់ផ្តែលក់ដីចំនួន ១,៩៨0,000 (មួយលានកៅសិបប្រាំបីម៉ឺនដុល្លារអាមេរិក) មកឱ្យខ្លួនវិញ និងសងថ្លៃចាក់ដីចំនួន ១១0,000 (ដប់មួយម៉ឺនដុល្លារអាមេរិក) និងការខូច ខាតជម្ងឺចិត្ត និងសេវាមេធាវីសរុបចំនួន ៥0,000 (ប្រាំម៉ឺនដុល្លារអាមេរិក) ដល់ខ្លួន។

-ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ថៃ បានឆ្លើយបំភ្លឺថា៖ ខ្លួនមិនបានដឹងពីបញ្ហាទិញលក់ដីនោះទេ តែខ្លួនដឹងថា

ឈ្មោះ [redacted] សុខន មានជំងឺប្រចាំកាយ ដោយរូបខ្លួនជាអ្នកដឹកគាត់ទៅមន្ទីរពេទ្យដោយផ្ទាល់ ចំពោះការដឹកទៅពេទ្យ ថ្ងៃណាគឺរូបខ្លួនមិនចាំនោះទេ ខ្លួនបានឆ្លើយបំភ្លឺត្រឹមតែអ្វីដែលបានដឹងតែប៉ុណ្ណោះ។

-ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ប៊ុននាង បានឆ្លើយបំភ្លឺថា៖ ខ្លួនសូមឆ្លើយបញ្ជាក់ជូនតុលាការថា អំឡុងពេលដែលឈ្មោះ [redacted] សុផល បានយកលិខិតទៅឱ្យផ្តិតមេដៃពីការទិញលក់ នោះគឺមិនមានវត្តមានឈ្មោះ [redacted] សុខន នោះទេ ដោយគាត់ពិតជាមិនបានចូលរួមមែន ព្រោះគាត់មានជំងឺប្រចាំកាយ ចំពោះការក្លែងឯកសារអ្នកណាជាធ្វើនោះគឺរូបខ្លួនមិនបានដឹងនោះទេ គឺរូបខ្លួនឆ្លើយបំភ្លឺត្រឹមតែអ្វីដែលខ្លួនបានដឹងតែប៉ុណ្ណឹង។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]

លោក [redacted] ជាមេធាវីតំណាងដោយអណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវលីង ឆ្លងតាមអង្គសវនាការឃើញថា៖ឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុផល និងឈ្មោះ ពៅ សុខន ពិតជាបានឆបោកប្រាក់ពីកូនក្តីខ្លួនដោយសារពួកគាត់ពុំបាន ទិញដីគ្រប់ចំនួនទេ ហើយបានក្លែងបន្លំលិខិតផ្ទេរសិទ្ធិកាន់កាប់ដីចំនួន ១៥ច្បាប់ ដើម្បីយកលុយរបស់ក្រុមហ៊ុនបន្ថែមទៀត។ ក្នុងនោះដីមួយចំនួន ដែលយកលុយពីក្រុមហ៊ុនទៅទិញហើយបែរជាដាក់ឈ្មោះ ខ្លួនឯងដោយមានបំណងយក ទៅលក់បន្តទៀត តួយ៉ាងដូចជាដីរបស់ឈ្មោះ [redacted] ឧត្តម និងដីរបស់ឈ្មោះ [redacted] សំណាង ជាដើម។ ម្យ៉ាងវិញ ទៀត ជនជាប់ចោទឈ្មោះ [redacted] សុខន មានចេតនាក្នុងការចរចាដោះស្រាយសំណងរដ្ឋប្បវេណីជាមួយកូនក្តីរបស់ខ្លួន ហើយក្នុងនាមខ្លួនជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យតុលាការមេត្តាផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខន ក្នុងស្ថានសម្រាលណាមួយដោយក្តីអនុគ្រោះ ព្រោះគាត់ជាមនុស្សម្នាក់ដែលមានការភ្ញាក់រលឹកនិងមាន ចេតនាក្នុងការដោះស្រាយរាល់បញ្ហាដែលបានកើតឡើង និងព្រមសហការជាមួយភាគីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៀតផង ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] សុផល ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី សូមសំណូមពរ សុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ទៅតាមច្បាប់ ព្រោះថាជនជាប់ចោទរូបនេះ ពុំមានចេតនាចរចារជាមួយភាគីខ្លួននោះទេ គឺបាននិយាយតែមាត់តែធាតុពិតបុគ្គលរូបនេះពុំមានចេតនាដើម្បីធ្វើការដោះស្រាយ ជាមួយភាគីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។

សេចក្តីសន្និដ្ឋានបី្ចងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសាកសួរដេញដោលនៅក្នុងអង្គសវនាការនេះ ឃើញថាជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ធា និង ជនជាប់ចោទឈ្មោះ [redacted] សុខន បានឆ្លើយពីទង្វើដែលខ្លួនបានប្រព្រឹត្តជូនអង្គសវនាការរួចរាល់ហើយ ។ ផ្អែកតាមចម្លើយសាក្សី និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង តំណាងអយ្យការនៅតែប្តឹងសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ធា ពីបទ **ឆបោក** និងបទ **ក្លែងឆ្លៀ (ស្នាមមេដៃ)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧**,មាត្រា**៣៧៨** និងមាត្រា**៦២៦**, មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ ។ និងប្តឹងសុំចំពោះជនជាប់ចោទ ឈ្មោះ [redacted] សុខន ពីបទ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៦២៦** , មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ និងសុំតុលាការផ្តន្ទា

ទោសជនជាប់ចោទទាំងពីរតាមច្បាប់ និងតាមអង្គបេតុជាក់ស្តែងដែលជនជាប់ចោទម្នាក់ៗបានប្រព្រឹត្ត។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខន ធ្លងតាមអង្គសវនាការ ឃើញថាកូនក្តី របស់ខ្លួនមិនបានក្លែងបន្លំឯកសារនោះទេ ចំពោះបញ្ហាកន្លងមកគឺកូនក្តីរបស់ខ្លួន ធ្វើតាមតែការបញ្ជា របស់ឈ្មោះ [redacted] រី តែប៉ុណ្ណោះ ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនមិនបានចូលរួមក្នុងការក្លែងបន្លំស្នាមមេដៃនោះឡើយ ហើយខ្លួនក៏មានសាក្សីដែលនៅថ្ងៃកើតហេតុដែលក្លែងបន្លំស្នាមមេដៃប្រជាពលរដ្ឋ ដែលបានលក់ដីនោះ គឺមិនមានវត្តមានកូនក្តីខ្លួនទេ។ ចំណុចនេះអាចបញ្ជាក់ថាកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តអំពើក្លែងបន្លំ ស្នាមមេដៃនោះឡើយ។ ចំណុចនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសូមស្នើសុំ ឱ្យតុលាការពិចារណា អំពីភស្តុតាងជាក់ស្តែង និងសាក្សីដែលដែលបានចូលរួមក្នុងសវនាការ ដែលអាចឱ្យកូនក្តីខ្លួនរួចផុត ពីការចោទប្រកាន់នេះផង ដោយក្តីអនុគ្រោះ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ធា ធ្លងតាមអង្គសវនាការ ឃើញថាកូនក្តី របស់ខ្លួនមិនបានក្លែងបន្លំឯកសារនោះទេ ចំពោះបញ្ហាកន្លងមកគឺកូនក្តីរបស់ខ្លួន ធ្វើតាមតែការបញ្ជា របស់ឈ្មោះ [redacted] រី តែប៉ុណ្ណោះ ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនមិនបានចូលរួមក្នុងការក្លែងបន្លំស្នាមមេដៃរបស់ប្រជាពលរដ្ឋដែលបានលក់ដីនោះទេ ហើយក្នុងរឿងនេះគឺកូនក្តីរបស់ខ្លួនបានដាក់ កម្ពស់អចលនវត្ថុរួចរាល់ហើយ ចំពោះអចលនវត្ថុទាំងនោះគឺ ត្រូវបានតុលាការចេញដីកាសម្រេចរក្សាការពារ លើទ្រព្យរបស់កូនក្តីខ្លួនរួចហើយដែរ។ ចំពោះរឿងនេះ គឺឈ្មោះ [redacted] រីក៏បានប្តឹងកូនក្តីរបស់ខ្លួនរួចហើយ ចំណែកតុលាការខេត្តកំពង់ស្ពឺក៏បានផ្តន្ទាទោសកូនក្តីខ្លួនម្តងហើយ។ ដោយកូនក្តីខ្លួនមានកូនដែលជាអនីតិជនក្នុងបន្ទុក ត្រូវទទួលភាពកិច្ចត្រូវសងបម្រុងធនាគារ និងមានបញ្ហាសុខភាពធ្ងន់ធ្ងរត្រូវការការព្យាបាលជាប្រចាំ ដូចមានក្នុងភស្តុតាងនូវលិខិតបញ្ជាក់សុខភាពលេខ ០៥ លបល ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ ចេញដោយមណ្ឌលអប់រំកែប្រែទី១ ។ ក្នុងរឿងនេះ ខ្លួនសូមឱ្យតុលាការពិចារណាលើកូនក្តីខ្លួន ដើម្បីឱ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់នេះផង។

សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ធា បាននិយាយសំដីចុងក្រោយបង្អស់ថា: ខ្លួនសំណូមពរឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ដល់រូបខ្លួនផង ព្រមទាំងឱ្យខ្លួនរួចផុតពីការចោទប្រកាន់ផង។

-ជនជាប់ចោទឈ្មោះ [redacted] សុខន បាននិយាយសំដីចុងក្រោយបង្អស់ថា: ខ្លួនសំណូមពរឱ្យតុលាការ មេត្តាជួយរកយុត្តិធម៌ដល់រូបខ្លួនផង ព្រមទាំងឱ្យខ្លួនរួចផុតពីការចោទប្រកាន់ផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយបំភ្លឺរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ:៣២៦៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ មកជំនុំជម្រះលើបណ្តឹងទាស់ ២២២ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស កើតថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧០ និងបណ្តឹងទាស់លេខ ២១៧ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] **សុខន** ភេទប្រុស កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧២ ជនជាតិខ្មែរ ដោយប្តឹងទាស់នឹងសាលក្រមលេខ ៣៥៣ "ឃ១" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។

ពីបទ **រឃោក និងបទក្លែងបន្លំ (ស្នាមមេដៃ)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧, មាត្រា៣៧៨ និងមាត្រា៦២៦, មាត្រា៦២៧ នៃក្រមព្រហ្មទណ្ឌ។

២-បណ្តឹងទាស់ **២២២** ចុះថ្ងៃទី**២៧** ខែធ្នូ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស កើតថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧០ និងបណ្តឹងទាស់លេខ **២១៧** ចុះថ្ងៃទី**២២** ខែធ្នូ ឆ្នាំ**២០២២** របស់ជនជាប់ចោទឈ្មោះ [redacted] **សុខន** ភេទប្រុស កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧២ ជនជាតិខ្មែរ ដោយប្តឹងទាស់នឹងសាលក្រមលេខ **៣៥៣** "ឃ១" ចុះថ្ងៃទី**១៥** ខែវិច្ឆិកា ឆ្នាំ**២០២២** គឺមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ អាចឲ្យតុលាការយកមកជំនុំជម្រះបាន។

៣-តាមដីកាសន្និដ្ឋានស្តាពរលេខ: **២៧០៧ អ.ឃ.ធ** ចុះថ្ងៃទី**២០** ខែកក្កដា ឆ្នាំ**២០២២** របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ថាកាលពីអំឡុងខែមិថុនា ឆ្នាំ**២០១៨** ឈ្មោះ [redacted] **រី** ឈ្មោះ [redacted] **សុខន** និងឈ្មោះ [redacted] **សុផល** ហៅ **ធា** បានធានារៀបចំទិញដីពីប្រជាពលរដ្ឋជាច្រើនគ្រួសារ មានទំហំសរុប ១២៣,៧៩៧.៩៩៩ ម^2 (ដប់ពីរម៉ឺនបីពាន់ប្រាំពីររយកៅសិបប្រាំពីរក្បៀសប្រាំបួនរយកៅសិបប្រាំបួន) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិពង្រ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឲ្យទៅ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវលីង [redacted] HSIU LING) ជនជាតិចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុន ហុងឡុងស៊ូ ឯ.ក (HONG LONG SHOE CO.,LTD) តែក្រោយពីបានលុយហើយ ឈ្មោះ [redacted] **រី** ភេទប្រុស កើត ថ្ងៃទី**១៥** ខែតុលា ឆ្នាំ**១៩៨២** ជនជាតិខ្មែរ ,ជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស កើតថ្ងៃទី**០៨** ខែសីហា ឆ្នាំ**១៩៧០** ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] **សុខន** ភេទប្រុស កើតថ្ងៃទី**០៩** ខែតុលា ឆ្នាំ**១៩៧២** ជនជាតិខ្មែរ បានទិញដីពីប្រជាពលរដ្ឋរួចដាក់ឈ្មោះរបស់ខ្លួន ហើយទុកលក់មិនព្រមផ្ទេរសិទ្ធិមកឲ្យក្រុមហ៊ុននោះឡើយ ម្យ៉ាងវិញ ទៀតជនជាប់ចោទបានក្លែងបន្លំស្នាមមេដៃ របស់ប្រជាពលរដ្ឋថែមទៀតផង ។ អំពើរបស់ជនជាប់ចោទទាំងបីនាក់នេះ គឺជាបទ **រឃោក** និងបទ **ក្លែងបន្លំ (ស្នាមមេដៃ)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ**២**០**១**៨ ពិតប្រាដកមែន។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ជា** ដែលបានឆ្លើយនាពេលសវនាការ ចម្លើយសាក្សីដែលបានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធី ព្រមទាំងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង តុលាការ

ពិចារណាឃើញថា: កាលពីអំឡុងឆ្នាំ២០១៨ ពិតជាមានអង្គហេតុរៀបចំទិញដីពីសំណាក់ជនជាប់ចោទឈ្មោះ [redacted] **រី** ឈ្មោះ[redacted] **សុខន** និង ឈ្មោះ [redacted] **សុផល** ហៅ **ធា** ពីប្រជាពលរដ្ឋជាច្រើនគ្រួសារ ដែលមានទីតាំងស្ថិតនៅភូមិពង្រ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីវលីង** ([redacted] HSIU LING) ជនជាតិ ចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុន ហុងឡុងស្ស ឯ.ក(HONG LONG SHOE CO.,LTD) ពិតប្រាកដមែន ។ ក្រោយពីបានលុយពីក្រុមហ៊ុនរួចហើយជនជាប់ចោទឈ្មោះ [redacted]**រី** ភេទប្រុស កើត ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៨២ ជនជាតិខ្មែរ, ជនជាប់ចោទឈ្មោះ[redacted]**សុផល** ហៅ **ធា** ភេទប្រុស កើតថ្ងៃទី០៨ ខែសីហា **ឆ្នាំ១៩៧០** ជនជាតិខ្មែរ និងជនជាប់ចោទ ឈ្មោះ [redacted] **សុខន** ភេទ ប្រុស កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧២ ជនជាតិខ្មែរ បានទិញដីពីប្រជាពលរដ្ឋរួចដាក់ឈ្មោះ របស់ខ្លួន ហើយទុកលក់មិនព្រមផ្ទេរកម្មសិទ្ធិមកឱ្យក្រុមហ៊ុននោះឡើយ ម្យ៉ាងវិញទៀត ជនជាប់ចោទក៏បានធ្វើការ ក្លែងបន្លំស្នាមមេដៃ របស់ប្រជាពលរដ្ឋថែមទៀតផង។ អំពើ និងសកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿងបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទរូបនេះ ពិតជាបានប្រព្រឹត្ត **អំពើទុច្ចរិត ឆបោក និងបទក្លែងបន្លំ (ស្នាមមេដៃ)** ដោយផ្ទាល់ប្រាកដមែន ហើយអំពើនេះបានបំពានទៅនឹងនីត្យានុកូលភាព នៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា**៣៧៧**, មាត្រា**៣៧៨** និងមាត្រា**៦២៦** ,មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះ គប្បីតុលាការពិចារណា អំពីការផ្តន្ទាទោសលើជនជាប់ ចោទរូបនេះ ស្របតាមព្យសនកម្ម ដែលខ្លួនបានប្រព្រឹត្តកន្លងមក។

៥-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខន** ដែលបានឆ្លើយនៅក្នុងអង្គសវនាការ ចម្លើយសារភ្ជាប់ ដែលបានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធី ព្រមទាំងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង តុលាការ ពិចារណា ឃើញថា: ទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខន** រូបនេះ គឺមានចេតនា និង ឧបាយកលទុច្ចរិតទៅលើក្រុមហ៊ុន ហុងឡុងស្ស ឯ.ក (HONG LONG SHOE CO.,LTD) ដែលនាំឱ្យខូចប្រយោជន៍របស់ក្រុមហ៊ុន ទង្វើរបស់ជនជាប់ចោទ ឈ្មោះ[redacted] **សុខន** គឺរៀបចំទិញដីពីប្រជាពលរដ្ឋជាច្រើនគ្រួសារ ដែលមានទីតាំងស្ថិតនៅភូមិពង្រ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីវលីង** (CHANG HSIU LING) ជនជាតិ ចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុន ហុងឡុងស្ស ឯ.ក(HONG LONG SHOE CO.,LTD) ប៉ុន្តែក្រោយពីទិញដីពីប្រជាពលរដ្ឋរួចហើយ បែជាដាក់ឈ្មោះរបស់ខ្លួន ហើយទុកលក់មិនព្រមផ្ទេរកម្មសិទ្ធិមកឱ្យក្រុមហ៊ុននោះឡើយ។ អំពើដែលបានប្រព្រឹត្តនេះ គឺជាអំពើទុច្ចរិត ឆបោក ហើយអំពើនេះគឺបានបំពានទៅនឹងនីត្យានុកូលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា**៣៧៧**, មាត្រា**៣៧៨** នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះ គប្បីតុលាការពិចារណា អំពីការផ្តន្ទាទោសលើជនជាប់ ចោទរូបនេះ ស្របតាមព្យសនកម្ម ដែលខ្លួនបានប្រព្រឹត្ត។

៦-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]**ស៊ីវលីង** ([redacted]HSIU LING) បានឆ្លើយនៅ

ដំណាក់កាលចៅក្រមស៊ើបសួរ ព្រមទាំងការរុះរកងរបស់លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអណត្តិឱ្យ ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅតែធ្វើការប្តឹងទាមទារសំណងរដ្ឋប្បវេណីពីជនជាប់ចោទ ទាំង ០៣ នាក់ដដែល និងបានធ្វើការសំណូមពរមកតុលាការ ដោយស្នើសុំឱ្យតុលាការមេត្តាផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ [redacted] **សុខន** ក្នុងស្ថានសម្រាលណាមួយដោយក្តីអនុគ្រោះ ព្រោះគាត់ជាមនុស្សម្នាក់ដែលមានការភ្ញាក់រលឹក និងមានចេតនាក្នុងការដោះស្រាយរាល់បញ្ហាដែលបានកើតឡើង និងព្រមសហការជាមួយភាគីខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីទៀតផង ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] **សុផល** ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ និង តំណាងឱ្យ ដើមបណ្តឹងរដ្ឋប្បវេណី សូមសំណូមពរ សុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ទៅតាមច្បាប់ ព្រោះថាជនជាប់ចោទ រូបនេះ ពុំមានចេតនាចរចារជាមួយភាគីខ្លួននោះទេ គឺបាននិយាយតែមាត់តែធាតុពិតបុគ្គលរូបនេះពុំមានចេតនាដើម្បីធ្វើ ការដោះស្រាយ ជាមួយភាគីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ចំពោះការប្តឹងសុំ និងសំណូមពររបស់ភាគីដើម បណ្តឹងរដ្ឋប្បវេណីនេះ គប្បីតុលាការនិងធ្វើការពិចារណា និងសម្រេចនៅក្នុងសេចក្តីសម្រេចនៃសាលក្រមនេះ។

៧-តាមការសាកសួរដេញដោលនៅក្នុងអង្គសវនាការ តាមចម្លើយសាក្សី និងភស្តុតាងនានាដែលមាននៅក្នុង សំណុំរឿងតុលាការពិចារណាឃើញថា ទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស កើតថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧០ ជនជាតិខ្មែរ គឺជនជាប់ចោទរូបនេះពិតជាមានចេតនាទុច្ចរិតប្រព្រឹត្តនូវអំពើ **ឆបោក** ទៅលើ ក្រុមហ៊ុនហុងឡុងស៊ូ ឯ.ក (HONG LONG SHOE CO.,LTD) ធ្វើឱ្យក្រុមហ៊ុនមានការខូចខ្ជះប្រយោជន៍ដោយសារតែ អំពើប្រព្រឹត្តរបស់ជនជាប់ចោទរូបនេះ គឺក្រោយពីបុគ្គលរូបនេះទទួលបានការរៀបចំទិញដីប្រជាពលរដ្ឋជាច្រើនគ្រួសារ ដែលមានទំហំសរុប ១២៣,៧៩៧.៩៩៩ ម^{2} (ដប់ពីរម៉ឺនបីពាន់ប្រាំពីររយកៅសិបប្រាំពីរក្បៀសប្រាំបួនរយកៅសិប ប្រាំបួន) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិពង្រ ឃុំស្រង់ ស្រុកគងពិសី **ខេត្តកំពង់ស្ពឺ** ឱ្យទៅឈ្មោះ ចាង ស៊ីវលីង (CHANG HSIU LING) ជនជាតិចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុន ហុងឡុង ស៊ូ ឯ.ក (HONG LONG SHOE CO.,LTD) ក្រោយពីទទួលបានប្រាក់ពីក្រុមហ៊ុន ចំនួន ៦៦០,០០០ (ហុកសិបប្រាំមួយម៉ឺនដុល្លារអាមេរិក) ជនជាប់ចោទ ពុំអាចរៀបចំដីឱ្យក្រុមហ៊ុនគ្រប់ចំនួននោះឡើយជាហេតុធ្វើឱ្យក្រុមហ៊ុនពុំអាចទទួលយកបានក្នុងការធ្វើអោចក្រឡើយ។ ពាក់ព័ន្ធនឹងអំពើ **ក្លែងបន្ធំ (ស្នាមមេដៃ)** តាមចម្លើយរបស់ឈ្មោះ [redacted] ហ៊ិន,ឈ្មោះ [redacted] សំណាង,ឈ្មោះ [redacted] ចាន់ធឿន, ឈ្មោះ [redacted] ប៉ក់ និងឈ្មោះ [redacted] មួច សុទ្ធតែបានឆ្លើយដូចគ្នាថា **នៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើ** ប្រាស់ដីធ្លីដែលមានស្នាមមេដៃពួកគាត់នោះគឺ ពួកគាត់បានអះអាងថា ពុំដែលបានផ្តិតមេដៃទេ គឺពួកគាត់ធ្លាប់បានផ្តិត មេដៃលើលិខិតកក់ប្រាក់តែប៉ុណ្ណោះ ក្រោយមកឈ្មោះ [redacted] សុផល បានយកលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនេះ ទៅចុះហត្ថលេខា លោកមេភូមិពង្រ ឈ្មោះ [redacted] សុង និងលោកមេឃុំស្រង់ ឈ្មោះ [redacted] ប៉ែង ដោយលោកមេភូមិ និង លោកមេឃុំ បានអះអាងថា **នៅពេលចុះហត្ថលេខា** គឺមានស្នាមមេដៃរបស់ប្រជាពលរដ្ឋរួចហើយ ដោយពុំបានផ្តិត មេដៃចំពោះមុខខ្លួននោះទេ ហើយខ្លួនក៏ពុំបានដឹងថាស្នាមមេដៃទាំងអស់ជាស្នាមមេដៃរបស់នរណាឡើយ។ ដូចនេះផ្អែក តាមចម្លើយសាក្សី និងភស្តុតាងនានាឃើញថាជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស ពិតជាបានប្រព្រឹត្ត អំពើទុច្ចរិត **ឆបោក** និង**បទក្លែងបន្ធំ (ស្នាមមេដៃ)** ដោយផ្ទាល់ដូចការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន

ហើយអំពើនេះបានបំពានទៅនឹងនីតិរាជ្យនៃក្បួលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា៣៧៧, មាត្រា ៣៧៨ និងមាត្រា៦២៦ ,មាត្រា៦២៧ នៃក្រមព្រហ្មទណ្ឌ ។

៨-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សុខន ភេទប្រុស កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧២ ជនជាតិខ្មែរ គឺជនជាប់ចោទរូបនេះពិតជាទទួលបានការរៀបចំទិញដីពីប្រជាពលរដ្ឋជាច្រើនគ្រួសារ ទំហំសរុប ១២៣,៧៩៧.៩៩៩ ម² (ដប់ពីរម៉ឺនបីពាន់ប្រាំពីររយកៅសិបប្រាំពីរក្បៀសប្រាំបួនរយកៅសិបប្រាំបួន) ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ពង្រ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីវលីង** ([redacted] HSIU LING) ជនជាតិចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុនហុងឡុងស៊ូ ឯ.ក (HONG LONG SHOE CO.,LTD) ប៉ុន្តែក្រោយពីទិញដីពី ប្រជាពលរដ្ឋរួចហើយ បែជាដាក់ឈ្មោះរបស់ខ្លួន ហើយទុកលក់មិនព្រមផ្ទេរកម្មសិទ្ធិមកឱ្យក្រុមហ៊ុននោះឡើយ។ ដូចនេះ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុខុន ដែលបានប្រព្រឹត្តនេះគឺជាអំពើទុច្ចរិត ឆបោក ហើយអំពើនេះ គឺបានបំពានទៅនឹងនីតិរាជ្យនៃក្បួលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា៣៧៧, មាត្រា៣៧៨ នៃ ក្រមព្រហ្មទណ្ឌ ។ ចំពោះអង្គហេតុដែលពាក់ព័ន្ធនឹងការ **ក្លែងបន្ថំ (ស្នាមមេដៃ)** របស់ជនជាប់ចោទឈ្មោះ [redacted] សុខន តុលាការពិចារណាឃើញថា នៅពេលដែលយកលិខិតផ្ទេរសិទ្ធិកាន់កាប់ទៅឱ្យប្រជាពលរដ្ឋផ្តិតមេដៃគឺឈ្មោះ [redacted] សុខន ពុំដែលបានចូលរួមនោះទេ ដោយជនជាប់ចោទឈ្មោះ [redacted] សុផល ជាអ្នករៀបចំធ្វើតែម្នាក់ឯងប៉ុណ្ណោះ ។ តាមចម្លើយ សាក្សីឈ្មោះ [redacted] ប៊ុនឆាង បានឆ្លើយបំភ្លឺថា៖ ខ្លួនសូមឆ្លើយបញ្ជាក់ជូនតុលាការថា អំឡុងពេលដែលឈ្មោះ [redacted] សុផល បានយកលិខិតទៅឱ្យផ្តិតមេដៃពីការទិញលក់ នោះគឺមិនមានវត្តមានឈ្មោះ [redacted] សុខន នោះទេ ដោយគាត់ពិតជាមិនបាន ចូលរួមមែន ព្រោះគាត់មានជំងឺប្រចាំកាយ ចំពោះការក្លែងឯកសារអ្នកណាជាធ្វើនោះគឺរូបខ្លួន មិនបានដឹងនោះទេ គឺរូបខ្លួន ឆ្លើយបំភ្លឺត្រឹមតែអ្វីដែលខ្លួនបានដឹងតែប៉ុណ្ណឹង។ ដូចនេះ ចំពោះអង្គហេតុ **ក្លែងបន្ថំ (ស្នាមមេដៃ)** របស់ជនជាប់ចោទ ឈ្មោះ [redacted] សុខន គឺពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដើម្បីធ្វើការផ្តន្ទាទោសទៅលើជនជាប់ចោទបាននោះទេ គប្បី តុលាការ សម្រេចឱ្យជនជាប់ចាទឈ្មោះ [redacted] សុខន រួចផុតពីបទចោទប្រកាន់នេះ។

៩-លោក [redacted] ជាមេធាវីតំណាងដោយអណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីវលីង** បានធ្វើសេចក្តី សន្និដ្ឋានថា ឆ្លងតាមអង្គសវនាការឃើញថា៖ឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន ពិតជាបាន ឆបោកប្រាក់ពីកូនក្តីខ្លួនដោយ សារពួកគាត់ពុំបាន ទិញដីគ្រប់ចំនួនទេ ហើយបានក្លែងបន្ថំលិខិតផ្ទេរសិទ្ធិកាន់កាប់ដីចំនួន ១៥ច្បាប់ ដើម្បីយកលុយរបស់ ក្រុមហ៊ុនបន្តែមទៀត។ ក្នុងនោះដីមួយចំនួន ដែលយកលុយពីក្រុមហ៊ុនទៅទិញហើយ បែរជាដាក់ឈ្មោះ ខ្លួនឯងដោយ មានបំណងយក ទៅលក់បន្តទៀត តួយ៉ាងដូចជាដីរបស់ឈ្មោះ ទឹម ឧត្តម និងដីរបស់ ឈ្មោះ [redacted] សំណាង ជាដើម។ ម្យ៉ាងវិញ ទៀត ជនជាប់ចោទឈ្មោះ [redacted] សុខន មានចេតនាក្នុងការចរចាដោះស្រាយ សំណងរដ្ឋប្បវេណីជាមួយកូនក្តីរបស់ខ្លួន ហើយក្នុងនាមខ្លួនជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យ តុលាការមេត្តាផ្តន្ទាទោស ជនជាប់ចោទឈ្មោះ [redacted] សុខន ក្នុងស្ថានសម្រាលណាមួយដោយក្តីអនុគ្រោះ ព្រោះគាត់ជា មនុស្សម្នាក់ដែលមានការភ្ញាក់រលឹកនិងមាន ចេតនាក្នុងការដោះស្រាយរាល់បញ្ហាដែលបានកើតឡើង និងព្រមសហ-

ការជាមួយភាគីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៀតផង ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] សុផល ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ និង តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី សូមសំណូមពរ សុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ទៅតាមច្បាប់ ព្រោះថាជនជាប់ចោទរូបនេះ ពុំមានចេតនាចរចារជាមួយភាគីខ្លួននោះទេ គឺបាននិយាយតែមាត់តែធាតុពិតបុគ្គលរូបនេះពុំមានចេតនាដើម្បីធ្វើការដោះស្រាយ ជាមួយភាគីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។

ចំពោះការសន្និដ្ឋានស្នើសុំរបស់ណេកកមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដោយស្នើសុំឲ្យតុលាការមេត្តាផ្តន្ទាទោស ជនជាប់ចោទឈ្មោះ [redacted] សុខន ក្នុងស្ថានសម្រាលណាមួយដោយក្តីអនុគ្រោះ ព្រោះគាត់ជាមនុស្សម្នាក់ដែលមានការភ្ញាក់រលឹកនិងមាន ចេតនាក្នុងការដោះស្រាយរាល់បញ្ហាដែលបានកើតឡើង និងព្រមសហការជាមួយភាគីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៀតផង ។ ការស្នើសុំនេះ គប្បីតុលាការនិងលើកយកមកធ្វើការពិចារណា និងសម្រេចដោយផ្អែកលើអត្តចរិកភាពស្មោះត្រង់ ការភ្ញាក់រលឹក ការទទួលស្គាល់កំហុសរបស់ជនជាប់ចោទ និងការសហការជាមួយភាគីដើមបណ្តឹងក្នុងការបញ្ចប់នូវវិវាទទាំងឡាយដែលបានកើតមាន។ ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] សុផល ណេកមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី សូមសំណូមពរ សុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ទៅតាមច្បាប់ ព្រោះថាជនជាប់ចោទរូបនេះ ពុំមានចេតនាចរចារជាមួយភាគីខ្លួននោះទេ គឺបាននិយាយតែមាត់តែធាតុពិតបុគ្គលរូបនេះពុំមានចេតនាដើម្បីធ្វើការដោះស្រាយ ជាមួយភាគីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ការស្នើសុំនេះ គប្បីតុលាការពិចារណា និងសម្រេចទៅតាមស្ថានភាពជាក់ស្តែងដែលជនជាប់ចោទបានប្រព្រឹត្ត។

១០-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសាកសួរដេញដោលនៅក្នុងអង្គសវនាការនេះ ឃើញថាជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** និង ជនជាប់ចោទឈ្មោះ [redacted] **សុខន** បានឆ្លើយពីទង្វើដែលខ្លួនបានប្រព្រឹត្តជូនអង្គសវនាការរួចរាល់ហើយ ។ ផ្អែកតាមចម្លើយសាក្សី និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង តំណាងអយ្យការនៅតែប្តឹងសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ពីបទ **រឃោក** និងបទ **ក្លែងធ្វើ (ស្នាមមេដៃ)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧**, មាត្រា**៣៧៨** និងហត្រា**៦២៦**, មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ ។ និងប្តឹងសុំចំពោះជនជាប់ចោទ ឈ្មោះ [redacted] **សុខន** ពីបទ **រឃោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៦២៦** , មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ និងសុំតុលាការផ្តន្ទាទោសជនជាប់ចោទទាំងពីរតាមច្បាប់ និងតាមអង្គហេតុជាក់ស្តែងដែលជនជាប់ចោទម្នាក់ៗបានប្រព្រឹត្ត។

ចំពោះការប្តឹងសុំ របស់តំណាងអយ្យការនេះ តុលាការនិងលើកយកមកធ្វើការពិចារណា ដោយផ្អែកទៅតាមអង្គហេតុដែលជនជាប់ចោទម្នាក់ៗបានប្រព្រឹត្ត និងពិចារណាទៅលើភស្តុតាងជាក់ស្តែងដែលមាននៅក្នុងសំណុំរឿង។

១១-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខន ឆ្លងតាមអង្គសវនាការ ឃើញថាកូនក្តី របស់ខ្លួនមិនបានក្លែងបន្លំឯកសារនោះទេ ចំពោះបញ្ហាកន្លងមកគឺកូនក្តីរបស់ខ្លួន ធ្វើតាមតែការបញ្ជា របស់ឈ្មោះ [redacted] រី តែប៉ុណ្ណោះ ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនមិនបានចូលរួមក្នុងការក្លែងបន្លំស្នាមមេដៃនោះឡើយ ហើយខ្លួនក៏មានសាក្សីដែលនៅថ្ងៃកើតហេតុដែលក្លែងបន្លំស្នាមមេដៃប្រជាពលរដ្ឋ ដែលបានលក់ដីនោះ គឺមានវត្តមានកូនក្តីខ្លួនទេ។ ចំណុចនេះអាចបញ្ជាក់ថាកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តអំពើក្លែងបន្លំ ស្នាមមេដៃនោះឡើយ។ ចំណុចនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសូមស្នើសុំ ឱ្យតុលាការពិចារណា អំពីភស្តុតាងជាក់ស្តែង និងសាក្សីដែលដែលបានចូលរួមក្នុងសវនាការ ដែលអាចឱ្យកូនក្តីខ្លួនរួចផុត ពីការចោទប្រកាន់នេះផង ដោយក្តីអនុគ្រោះ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ឆ្លងតាមអង្គសវនាការ ឃើញថាកូនក្តី របស់ខ្លួនមិនបានក្លែងបន្លំឯកសារនោះទេ ចំពោះបញ្ហាកន្លងមកគឺកូនក្តីរបស់ខ្លួន ធ្វើតាមតែការបញ្ជា របស់ឈ្មោះ [redacted] រី តែប៉ុណ្ណោះ ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនមិនបានចូលរួមក្នុងការក្លែងបន្លំស្នាមមេដៃរបស់ប្រជាពលរដ្ឋដែលបានលក់ដីនោះទេ ហើយក្នុងរឿងនេះគឺកូនក្តីរបស់ខ្លួនបានដាក់ កម្ពស់អចលនវត្ថុរួចរាល់ហើយ ចំពោះអចលនវត្ថុទាំងនោះគឺ ត្រូវបានតុលាការចេញដីកាសម្រេចរក្សាការពារ លើទ្រព្យរបស់កូនក្តីខ្លួនរួចហើយដែរ។ ចំពោះរឿងនេះ គឺឈ្មោះ [redacted] រីក៏បានប្តឹងកូនក្តីរបស់ខ្លួនរួចហើយ ចំណែកតុលាការខេត្តកំពង់ស្ពឺក៏បានផ្តន្ទាទោសកូនក្តីខ្លួនម្តងហើយ។ ដោយកូនក្តីខ្លួនមានកូនដែលជាអនីតិជនក្នុងបន្ទុក ត្រូវទទួលកាតព្វកិច្ចត្រូវសងបមណុលធនាគារ និងមានបញ្ហាសុខភាពធ្ងន់ធ្ងរត្រូវការការព្យាបាលជាប្រចាំ ដូចមានក្នុងភស្តុតាងនូវលិខិតបញ្ជាក់សុខភាពលេខ ០៤ លបល ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ ចេញដោយមណ្ឌលអប់រំកែប្រែទី១ ។ ក្នុងរឿងនេះ ខ្លួនសូមឱ្យតុលាការពិចារណាលើកូនក្តីខ្លួន ដើម្បីឱ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់នេះផង។

ការសន្និដ្ឋានស្នើសុំរបស់លោកមេធាវី ការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរ ដោយបានសំណូមពរឱ្យកូនក្តីរបស់ខ្លួនរួចផុតពីការចោទប្រកាន់ តុលាការពិចារណាឃើញថា អំពើប្រព្រឹត្តដែលជនជាប់ចោទទាំងពីរនាក់ដែលបានប្រព្រឹត្ត គឺមានធាតុផ្សំបទល្មើសព្រហ្មទណ្ឌគ្រប់គ្រាន់ ដោយជនជាប់ចោទទាំងពីរនាក់គឺមានចេតនាផង ឧបាយកលទុច្ចរិតទៅលើក្រុមហ៊ុនហុងឡុងស្ស ឯ.ក (HONG LONG SHOE CO.,LTD) ដែលនាំឱ្យក្រុមហ៊ុនមានខូចប្រយោជន៍ ដែលកើតចេញពីអំពើប្រព្រឹត្តរបស់អ្នកទាំងពីរ ទង្វើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខន** និងជនចាប់ចោទឈ្មោះ [redacted] **សុផល** គឺជាអំពើទុច្ចរិត **ឆបោក** ហើយអំពើនេះគឺបានបំពានទៅនឹងនីតិានុកូលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា៣៧៧, មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។ ចំពោះទង្វើប្រព្រឹត្តមួយទៀតដែលជនជាប់ចោទឈ្មោះ [redacted] **សុផល** បានព្រឹត្តគឺអំពើ **ក្លែងបន្លំ (ស្នាមមេដៃ)** អំពើប្រព្រឹត្តនេះក៏មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដើម្បីធ្វើការផ្តន្ទាទោសលើជនជាប់ចោទរូបនេះ ផ្អែកតាមចម្លើយរបស់ឈ្មោះ [redacted] ហ៊ិន,ឈ្មោះ [redacted] សំណាង,ឈ្មោះ [redacted] ចាន់ធឿន, ឈ្មោះ [redacted] ប៉ក់ និងឈ្មោះ [redacted] ទូច សុទ្ធតែបានឆ្លើយដូចគ្នាថា នៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើ

ប្រាស់ដីធ្លីដែលមានស្នាមមេដៃពួកគាត់នោះគឺ ពួកគាត់បានអះអាងថាពុំដែលបានផ្តិតមេដៃទេ គឺពួកគាត់ធ្លាប់បានផ្តិតមេដៃលើលិខិតកក់ប្រាក់តែប៉ុណ្ណោះ ក្រោយមកឈ្មោះ [redacted] សុផល បានយកលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនេះទៅចុះហត្ថលេខា លោកមេភូមិពង្រ ឈ្មោះ [redacted] សុង និងលោកមេឃុំស្រង់ ឈ្មោះ [redacted] ប៉ែង ដោយលោកមេភូមិ និងលោកមេឃុំ បានអះអាងថា នៅពេលចុះហត្ថលេខា គឺមានស្នាមមេដៃរបស់ប្រជាពលរដ្ឋរួចហើយ ដោយពុំបានផ្តិតមេដៃចំពោះមុខខ្លួននោះទេ ហើយខ្លួនក៏ពុំបានដឹងថាស្នាមមេដៃទាំងអស់ជាស្នាមមេដៃរបស់នរណាឡើយ។ ដូចនេះផ្អែកតាមចម្លើយសាក្សី និងភស្តុតាងនានាឃើញថាជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស ពិតជាបានប្រព្រឹត្ត**អំពើទុច្ចរិត ក្លែងបន្លំ (ស្នាមមេដៃ)** ពិតប្រាកដមែន ។

១២-ជនជាប់ចោទទាំងពីររូបបានសំណូមពរសំដីចុងក្រោយ សុំឲ្យតុលាការ មេត្តាជួយរកយុត្តិធម៌ដល់រូបខ្លួនផង ព្រមទាំងឲ្យខ្លួនរួចផុតពីការចោទប្រកាន់នេះផង។ ចំពោះការសំណូមពរសំដីចុងក្រោយរបស់ជនជាប់ចោទទាំងពីររូបនេះ តុលាការនឹងធ្វើការពិចារណា ស្របតាម**អំពើ** និងព្យសនកម្ម ដែលអ្នកទាំងពីរបានប្រព្រឹត្តកន្លងមក។

១៣-អំពើ និង សកម្មភាពរបស់ជនជាប់ចោទទាំងពីរបានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់សន្តិសុខរបៀបរៀបរយល្អរបស់សង្គម និងប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះដែលច្បាប់បានការពារ និងតម្រូវឲ្យផ្តន្ទាទោស។

១៤-ពេលធ្វើសកម្មភាពប្រព្រឹត្តបទល្មើស ជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ប្រព្រឹត្ត**អំពើ**ល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួនហើយជនជាប់ចោទជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវ**អំពើ**របស់ខ្លួនដែលបានប្រព្រឹត្ត។

១៥-ជនជាប់ចោទឈ្មោះ [redacted] **សុខន** ទើបតែបានប្រព្រឹត្តបទល្មើសជាលើកទីមួយ និងមិនដែលធ្លាប់តុលាការផ្តន្ទាទោសពីមុនមកនោះទេ ម្យ៉ាងវិញទៀតដោយជនជាប់ចោទព្យាយាមចរចាដោះស្រាយបញ្ហាវិវាទនានាជាមួយភាគដើមបណ្តឹងរដ្ឋវេណី ហើយជនជាប់ចោទកំពុងមានជំងឺប្រចាំកាយ មានកូនជាអនីតិជនក្នុងបន្ទុកដែលត្រូវចិញ្ចឹមបីបាច់ថែរក្សាថែមទៀតផង ។ មួយវិញទៀតដោយមានការសំណូមពរពីសំណាក់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដោយស្នើសុំឲ្យតុលាការមេត្តាផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខន ក្នុងស្ថានសម្រាលណាមួយដោយក្តីអនុគ្រោះ ព្រោះគាត់ជាមនុស្សម្នាក់ដែលមានការភ្ញាក់រលឹកនិងមានចេតនាក្នុងការដោះស្រាយរាល់បញ្ហាដែលបានកើតឡើង និងព្រមសហការជាមួយភាគីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៀតផង។ ចំណុចនេះ គប្បីតុលាការពិចារណា អំពីការផ្តន្ទាទោស និងការព្យួរទោសដល់ជនជាប់ចោទរូបនេះដោយអនុលោមតាមមាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

១៦-ជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស ទើបតែបានប្រព្រឹត្តបទល្មើសជាលើកទីមួយ និងមិនដែលធ្លាប់តុលាការផ្តន្ទាទោសពីមុនមកនោះទេ ហើយជនជាប់ចោទកំពុងមានជំងឺប្រចាំកាយ មានកូនជាអនីតិជន

ក្នុងបន្ទុកដែលត្រូវចិញ្ចឹមបីបាច់ថែរក្សា ថែមទៀតផង ចំណុចនេះ គប្បីតុលាការពិចារណា អំពីការព្យួរទោសដល់ជនជាប់ចោទដោយអនុលោមតាមមាត្រា**១០៧** និងមាត្រា**១០៨** នៃក្រមព្រហ្មទណ្ឌ។

១៧-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស ជនជាតិខ្មែរ ពីបទ **រាបាក** និងបទ **ក្លែងបន្លំ (ស្នាមមេដៃ)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧**,មាត្រា**៣៧៨** និងមាត្រា**៦២៦** ,មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ។

-ព្រមទាំងមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុខន** ភេទប្រុស ជនជាតិខ្មែរ ពីបទ **រាបាក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧**, មាត្រា**៣៧៨** នៃក្រមព្រហ្មទណ្ឌ។

<u>ហេតុផ្ដួចផ្ដើមសម្រេច</u>

១-ទទួលពាក្យបណ្តឹងទាស់លេខ ២២២ ចុះថ្ងៃទី**២៧** ខែធ្នូ ឆ្នាំ**២០២២** របស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស កើតថ្ងៃទី**០៨** ខែសីហា ឆ្នាំ**១៩៧០** និងបណ្តឹងទាស់លេខ **២១៧** ចុះថ្ងៃទី**២២** ខែធ្នូ ឆ្នាំ**២០២២** របស់ជនជាប់ចោទឈ្មោះ[redacted] **សុខន** ភេទប្រុស កើតថ្ងៃទី**០៩** ខែតុលា ឆ្នាំ**១៩៧២** ជនជាតិខ្មែរ ទុកជាត្រឹមត្រូវតាមកំណត់ច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ៣៤៤៣ "**ឃ១**" ចុះថ្ងៃទី**១៥** ខែ**វិច្ឆិកា** ឆ្នាំ**២០២២**ត្រង់ចំណុចទី**១** ,**ទី២** , **ទី៤** , **ទី៥** និង**ទី៦** នៃសេចក្តីសម្រេចទុកជាបានការដដែល។

៣.កែប្រែចំណុចទី**៣** "**ក និង ខ**" នៃសាលក្រមព្រហ្មទណ្ឌលេខ ៣៤៤៣ "**ឃ១**" ចុះថ្ងៃទី**១៥** ខែ**វិច្ឆិកា** ឆ្នាំ**២០២២** ដូចខាងក្រោម៖

ក-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ភេទប្រុស កើតថ្ងៃទី**០៨** ខែសីហា ឆ្នាំ**១៩៧០** ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន **០២ឆ្នាំ** (**ពីរឆ្នាំ**) **តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន ១៨ខែ (ដប់ប្រាំបីខែ) ទោសដែលនៅសល់ត្រូវអនុវត្តទោសព្យួរធម្មតា** ពីបទ **រាបាក** និងបទ **ក្លែងបន្លំ** (**ស្នាមមេដៃ**) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧**, មាត្រា**៣៧៨**និងមាត្រា**៦២៦** ,មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ។

ខ-ឱ្យឈ្មោះ[redacted] **សុខន** ភេទប្រុស កើតថ្ងៃទី**០៩** ខែតុលា ឆ្នាំ**១៩៧២** ជនជាតិខ្មែរ **រួចខ្លួន** ពីបទ **ក្លែងបន្លំ** (**ស្នាមមេដៃ**)ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៦២៦** ,មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌនិងមាត្រា**៣៥០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

គ-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សុខន** ភេទប្រុស កើតថ្ងៃទី**០៩** ខែតុលា ឆ្នាំ**១៩៧២** ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន **០១ឆ្នាំ**(**មួយឆ្នាំ**) **តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន ០២**(**ពីរខែ**) **ទោសដែលនៅសល់ត្រូវអនុវត្តទោសព្យួរធម្មតា** ពីបទ **រាបាក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧**, មាត្រា**៣៧៨** និងមាត្រា**១០៧**,មាត្រា**១០៨** នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនាថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ**២០២៣** **ចំពោះមុខជនជាប់ចោទឈ្មោះ** [redacted] **សុខន**

ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ធា, ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ, ចាត់ទុក
ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវលីង ([redacted] HSIU LING), ចំពោះមុខមេធាវីតំណាងដោយអាណត្តិ
ឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា៖ [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា៖ [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner